**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ........ សហវ.ក.......

រាជធានីភ្នំពេញ,ថ្ងៃទី ...... ខែ ...... ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ:** ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យា ស្តីពីការងារជួសជុលខួបដោយក្រាលល្បាយថ្មភ្នំផ្លូវចំនួន ០១ខ្សែ ប្រវែង១៥ ៥០០ម ទទឹងខ្នងលើ ០៥ម កម្រាស់ ០,២ម និងសាងសង់លូមូលចំនួន ០១កន្លែង ស្ថិតក្នុងខេត្តកំពត។

**យោង:** - លិខិតលេខ ១៩០៣ សហវ.អថ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- កំណត់ហេតុចរចាថ្លៃ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ របស់ គ.ល ក្រសួងអភិវឌ្ឍន៍ជនបទ
- លិខិតលេខ ១០០៥/១៦ ក.អ.ជ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការប្រគល់កិច្ចសន្យា ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពត ដើម្បីធ្វើការងារជួសជុលខួបដោយក្រាលល្បាយថ្មភ្នំផ្លូវចំនួន ០១ខ្សែ (ផ្លូវដងទង់-ក្រាំងលាវ) ប្រវែង ១៥ ៥០០ម ទទឹងខ្នងលើ ០៥ម កម្រាស់ ០,២ម និងសាងសង់លូមូលចំនួន ០១កន្លែង ស្ថិតក្នុងឃុំអង្គរមាស ឃុំមានរិទ្ធិ និងឃុំដងទង់ ស្រុកដងទង់ ខេត្តកំពត ក្នុងតម្លៃសរុបចំនួន១ ០៦៩ ៥០០ ០០០ រៀល (មួយប៊ីលាន ហុកសិបប្រាំបួនលាន ប្រាំរយពាន់រៀលគត់) ជាតម្លៃកិច្ចសន្យា។

ការជួលបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ជាដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបានត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការអនុវត្តបន្តឱ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ជ. ទេសរដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

រដ្ឋលេខាធិការ

វង្សី វិស្សុត

**ចម្លងជូន:**
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- សាលាខេត្តកំពត
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពត
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពត
- ឯកសារ-កាលប្បវត្តិ